# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ: ២៩០ "ផ១"

ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩

-សំណុំរឿងព្រហ្មទណ្ឌលេខ: ៦២៤៦

ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៨

-សំណុំរឿងស៊ើបសួរលេខ: ៣៦០៩

ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៨

-សំណុំរឿងជំនុំជម្រះលេខ: ២៩០

ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង០៨ និង ៣០នាទីព្រឹក នៅសាលសវនាការទី២ ដោយមានសមាសភាពដូចតទៅ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះសាលាដំបូងរាជធានីភ្នំពេញ

-លោក [redacted] ចៅក្រមប្រឹក្សាសាលាដំបូងរាជធានីភ្នំពេញ

-លោក [redacted] ចៅក្រមប្រឹក្សាសាលាដំបូងរាជធានីភ្នំពេញ

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៦២៤៦ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទ:

១/-ឈ្មោះ [redacted] វិចិត្រា ហៅ តូ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតខ្មែរ មុខរបរសិស្ស មានទីកន្លែងកំណើត សង្កាត់ [redacted] រាជធានីភ្នំពេញ និងទីលំនៅបច្ចុប្បន្ន ផ្ទះ [redacted] ធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សាន្ត "រស់" ម្តាយឈ្មោះ [redacted] ចាន់ណារី "រស់" នៅលីវ ជានីតិជន។ (ក្នុងឃុំ)

-ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ៨២៣១ "ច" ដ.ឃ.ជ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៨។

-ដោយមានលោក [redacted] ជាមេធាវីការពារឱ្យជនជាប់ចោទ។

-ជាប់ចោទពីបទ: លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច ភូមិ៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២/-ឈ្មោះ [redacted] សុវណ្ណឧត្តមវង្សី ហៅ តូ ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត [redacted] រាជធានីភ្នំពេញ និងទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ពៅ "ស្លាប់" ម្តាយឈ្មោះ [redacted] សុវណ្ណារ៉ា "រស់" ប្រពន្ធឈ្មោះ [redacted] ខេមរិទ្ធ មានកូន០២នាក់ ជានីតិជន។ (ក្រៅឃុំ)

-ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ (លើកទី១ ឆក់ទូរស័ព្ទ នគរបាលខណ្ឌទួលគោកចាប់ខ្លួនថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៥ និងលើកទី២ ឆក់កាបូបជនជាតិចិន នគរបាលខណ្ឌដូនពេញចាប់ខ្លួនថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៦)។

-ដោយមានលោក [redacted] ជាមេធាវីការពារឱ្យជនជាប់ចោទ។



Scanned with CamScanner

-ជាប់ចោទពីបទ: លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុច ភូមិ៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

## អង្គហេតុនៃរឿងមានដូចតទៅ

-កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល១៣ និង១០នាទី ជនរងគ្រោះមិនស្គាល់ឈ្មោះ ភេទស្រី ជាជនបរទេស កំពុងដើរនៅចំណុចផ្លូវលេខ២១ កែងផ្លូវលេខ២៩៤ ក្រុមទី២៦ ភូមិ៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ស្រាប់តែជនត្រូវចោទឈ្មោះ [redacted] សុវណ្ណឧត្តមវង្ស៊ី ហៅ តូ ភេទប្រុស អាយុ២៤ឆ្នាំ បានបើកម៉ូតូមួយគ្រឿងម៉ាក SUZUKI NEX ពណ៌ក្រហម ផលិតឆ្នាំ២០១៨ ឌុបជនត្រូវចោទឈ្មោះ [redacted] វិចិត្រា ហៅ តួ ភេទប្រុស អាយុ២០ឆ្នាំ ទៅអែបជនរងគ្រោះ ហើយជនជាប់ចោទដែលអង្គុយនៅខាងក្រោយ បានធ្វើសកម្មភាពឆក់កាបូបជនរងគ្រោះបានសម្រេច ចំណែកជនត្រូវចោទឈ្មោះ វ័ន្ត ភេទប្រុស អាយុប្រហែល២៥ឆ្នាំ បានបើកម៉ូតូម៉ាកហុង ដាស្កុបពីរពណ៌ស ស៊េរីឆ្នាំ២០១៨ ជាអ្នកបិទគូទពីក្រោយ រួចនាំគ្នាបើកម៉ូតូគេចខ្លួនតែម្តង។ លុះដល់ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង៩ និង៤០នាទី កម្លាំងសមត្ថកិច្ចបានឃាត់ខ្លួនជនត្រូវចោទឈ្មោះ [redacted] វិចិត្រា ហៅ តួ បាននៅចំណុចក្បែរផ្សារ៧មករា ផ្លូវលេខ៦១៤ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ពេលធ្វើតេស្តទឹកនោមជនត្រូវចោទឈ្មោះ [redacted] វិចិត្រា ឃើញមានផ្ទុកសារធាតុញៀន។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ៣៦៤៩ អយណ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ១៧៦ អ.យ.ន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ៣០៨ (ខ) ដ.ដ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ [redacted] វិចិត្រា បានឆ្លើយថា: កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង១៣ និង១០នាទី ខ្លួននិងឈ្មោះ [redacted] សុវណ្ណឧត្តមវង្ស៊ី ពិតជាបានធ្វើសកម្មភាពឆក់កាបូបស្ពាយពីជនបរទេសម្នាក់ ភេទស្រី ដែលកំពុងដើរជាមួយម្នាក់ទៀត ជាជនជាតិខ្មែរ។ ដោយឈ្មោះ [redacted] សុវណ្ណឧត្តមវង្ស៊ី ជាអ្នកបើកម៉ូតូ ហើយវាបានប្រាប់ខ្លួនឱ្យឆក់កាបូបគេ ទើបខ្លួនឆក់។ ខ្លួនឆក់គេបានសម្រេចប្រហែលជាមួយខែ ទើបសមត្ថកិច្ចស្រាវជ្រាវតាមវីដេអូដែលខ្លួនបានឆក់ ពេលឆក់កាបូបបានហើយ នៅក្នុងកាបូបនោះ គឺមានទូរស័ព្ទចំនួន០១គ្រឿង និងប្រាក់ចំនួន២០០ ដុល្លាអាមេរិក ខ្លួនបានតែ ៥០(ហាសិប) ដុល្លាទេ សល់ប៉ុន្មានត្រូវឈ្មោះ ឧត្តមវង្ស៊ី យកទាំងអស់។ ពួកខ្លួនទើបតែធ្វើសកម្មភាពឆក់ជាលើកទីមួយប៉ុណ្ណោះ។ ពេលដែលសមត្ថកិច្ចចាប់ខ្លួនបានគឺនៅលើខ្លួនពុំមានដកហូតអ្វីទេ។

តាមអំណានរបាយការណ៍សំយោគរបស់ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាលបានបញ្ជាក់ថា: កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង១៣ និង១០នាទី មានករណី: អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រើអំពើហឹង្សា ប្រព្រឹត្តនៅចំណុចផ្លូវលេខ២១កែងផ្លូវលេខ២៩៤ ក្រុម២៦ ភូមិទី៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ពីជនរងគ្រោះមិនស្គាល់អត្តសញ្ញាណជាជនបរទេស ភេទស្រី កំពុងដើរស្ពាយកាបូប បង្កឡើងដោយជនសង្ស័យចំនួន០៣នាក់ ជិះម៉ូតូចំនួន០២គ្រឿង គឺឈ្មោះ [redacted] សុវណ្ណឧត្តមវង្ស៊ី ហៅ តូ ភេទប្រុស អាយុ២៤ឆ្នាំ ជិះម៉ូតូម៉ាក SUZUKI NEX ពណ៌ក្រហម ស ស៊េរីឆ្នាំ២០១៨ មិនចាំស្លាកលេខឌុបឈ្មោះ [redacted] វិចិត្រា ហៅ តួ ភេទប្រុស អាយុ២០ឆ្នាំ ម៉ូតូនេះជារបស់ឈ្មោះ [redacted] សុវណ្ណឧត្តមវង្ស៊ី ហៅ តូ។ ឈ្មោះ វ័ន្ត ភេទប្រុស អាយុ២៥ឆ្នាំ ប្រើម៉ូតូស៊េរីឆ្នាំ... ៤២

២២ ២១៦ ជិះម៉ូតូម៉ាកហុងដា ស្កុបពី ពណ៌ស ស៊េរីឆ្នាំ២០១៨ មិនចាំស្លាកលេខ ម្នាក់ឯង ម៉ូតូនេះជារបស់ឈ្មោះ រ័ត្ន នៅពេលជនសង្ស័យជិះម៉ូតូមកដល់ចំណុចផ្លូវលេខ២១ កែងផ្លូវលេខ២៦៤ ភូមិ៤ ក្រុមទី២៦ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ក៏បានឃើញជនរងគ្រោះជនបរទេស មិនស្គាល់អត្តសញ្ញាណ ភេទស្រី កំពុងដើរពីរនាក់ក្នុងនោះមានម្នាក់ស្ពាយកាបូបមួយ ភ្លាមនោះជនសង្ស័យឈ្មោះ [redacted] សុវណ្ណឧត្តមវង្សី ហៅ តូ បានឃើញក៏បើកម៉ូតូចូលទៅជិតជនរងគ្រោះ ហើយជនសង្ស័យឈ្មោះ [redacted] វិចិត្រា ហៅ តូ ដែលអង្គុយអែបខាងក្រោយ ក៏បានធ្វើសកម្មភាពឆក់កាបូបស្ពាយពីជនរងគ្រោះបានសម្រេច ចំណែកឈ្មោះ រ័ត្ន ជិះម៉ូតូបិទគូថពីក្រោយ រួចនាំគ្នាជិះម៉ូតូគេចខ្លួនបាត់អស់។ ក្រោយពីបានពិនិត្យកាមេរ៉ាសុវត្ថិភាពព្រមទាំងមានការផ្តល់ពត៌មានពីកម្លាំងមូលដ្ឋានសម្ងាត់ កម្លាំងជំនាញរបស់ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាលរាជធានីភ្នំពេញ បានធ្វើការស្រាវជ្រាវនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង៩ និង៤០នាទី កម្លាំងយើងឃាត់បានជនសង្ស័យចំនួនម្នាក់ ឈ្មោះ [redacted] វិចិត្រា ហៅ តូ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ នៅចំនុចមុខក្បែរផ្សារ៧មករា ផ្លូវលេខ៦១៤ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ បានប្រព្រឹត្តបទល្មើសខាងលើ ហើយបញ្ជូនមកកាន់ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាលរាជធានីភ្នំពេញ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងឯកសារផ្សេងៗដែលមាននៅក្នុងសំណុំរឿងតំណាងអយ្យការស្នើសុំតំកល់ការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរលេខ: ១៧៦អ.យ.ន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ ទុកជាបានការដដែល។

លោក [redacted] មេធាវីការពារឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារឱ្យកូនក្តីខ្លួនថា: ឆ្លងតាមការពិភាក្សាដេញដោលនាពេលសវនាការ ឃើញថាកូនក្តីខ្លួនពិតជាបានសារភាពថាខ្លួនពិតជាបានប្រព្រឹត្តដូចបទចោទប្រកាន់មែន ប៉ុន្តែដោយសារកូនក្តីខ្លួនទើបតែប្រព្រឹត្តជាលើកទីមួយ និងដោយសារការអូសទាញពីមិត្តភ័ក្រ្ត ហើយកូនក្តីខ្លួនមានការស្តាយក្រោយដែលបានប្រព្រឹត្ត ដូចនេះខ្លួនសុំឱ្យប្រធានក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយទោសដល់ក្តីខ្លួន និងសុំកែពីការចោទមាត្រា ៣៥៧ មកចោទប្រកាន់មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌវិញដោយក្តីអនុគ្រោះផង។

ជនជាប់ចោទឈ្មោះ [redacted] វិចិត្រា បាននិយាយសំដីចុងក្រោយបង្អស់របស់ខ្លួនថា: ស្នើសុំតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យខ្លួនផង ខ្លួនដឹងទោសកំហុសហើយ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានរបាយការណ៍សំយោគ

-ក្រោយពីបានពិនិត្យឯកសារ និងវត្ថុតាងនានា

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់អយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១/ជនជាប់ចោទឈ្មោះ [redacted] វិចិត្រា បានឆ្លើយសារភាពចំពោះការចោទប្រកាន់ថា សកម្មភាពនេះខ្លួនធ្វើរួមជាមួយឈ្មោះ [redacted] សុវណ្ណឧត្តមវង្សី ប្រាកដមែនពោលគឺបានឆក់កាបូបរបស់ជនបរទេសម្នាក់ ភេទស្រីមិនស្គាល់អត្តសញ្ញាណបានសំរេច រីឯជនរងគ្រោះ គឺមិនមានដួលទេ ហើយក្នុងកាបូបនោះ គឺមានទូរស័ព្ទចំនួន១ និងប្រាក់ចំនួន ២០០ ដុល្លាអាមេរិក ខ្លួនបានតែ៥០ដុល្លាទេ សល់ប៉ុន្មានត្រូវឈ្មោះ ឧត្តមវង្សី យកទាំងអស់។ សកម្មភាពខាងលើនេះត្រូវបាន

ចាប់ខ្លួន ក្រោយរយៈពេលប្រហែលជាកន្លះខែដោយសារសមត្ថកិច្ចបានពិនិត្យកាមេរ៉ាសុវត្ថិភាព។ ការសារភាពខាងលើនេះមានមូលដ្ឋានគ្រប់គ្រាន់សំរាប់ដាក់ទោសជនជាប់ចោទបានតាមច្បាប់។

២/ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណឧត្តមវង្សី បានរត់គេចខ្លួនបាត់និងមានសាវតាជាតិគ្រប់គ្រាន់ គប្បីតុលាការចេញសេចក្តីសម្រេចពិសេស ចាប់ខ្លួន-ឃុំខ្លួនលើជននេះតាមនីតិវិធី។

៣/សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការស្នើសុំតំកល់ការចោទប្រកាន់ និងសុំឱ្យតុលាការពិនិត្យ និងសម្រេចតាមច្បាប់នោះ មានលក្ខណៈសមហេតុសមផលហើយ គប្បីតុលាការពិនិត្យ និងសម្រេចតាមច្បាប់។

៤/សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទស្នើសុំតុលាការបន្ធូរបន្ថយទោសឱ្យកូនក្តីខ្លួនផង នោះគប្បីតុលាការពិនិត្យ និងសម្រេចតាមច្បាប់។

៥/សំដីចុងក្រោយរបស់ជនជាប់ចោទស្នើសុំឱ្យតុលាការបន្ធូរបន្ថយទោស នោះគប្បីតុលាការពិនិត្យនិងសម្រេចតាមច្បាប់។

៦/មានពិរុទ្ធភាពគ្រប់គ្រាន់ចោទប្រកាន់លើឈ្មោះ [redacted] វិចិត្រា ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ ពីបទៈ លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងឈ្មោះ [redacted] សុវណ្ណឧត្តមវង្សី ហៅ សុវណ្ណ ឧត្តមវង្សី ហៅ តួ ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ ពីបទៈ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុច ភូមិ៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៨។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ និង មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ហេតុដូច្នេះសម្រេច**

១/-ផ្តន្ទាទោសលើឈ្មោះ [redacted] វិចិត្រា ហៅ តួ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] សុវណ្ណឧត្តមវង្សី ហៅ សុវណ្ណ ឧត្តមវង្សី ហៅ តួ ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗចំនួន ០៥ (ប្រាំ) ឆ្នាំ ពីបទៈ លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច ភូមិ៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៨។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២/ចេញដីកាបង្គាប់ឱ្យចាប់ខ្លួន-ឃុំខ្លួនលើឈ្មោះ [redacted] សុវណ្ណឧត្តមវង្សី ហៅ សុវណ្ណ ឧត្តមវង្សី ហៅ តួ (មានសាវតាជាតិគ្រប់គ្រាន់) តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣/-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២២ ខែមេសា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វិចិត្រា ហៅ តួ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សុវណ្ណឧត្តមវង្សី ហៅ សុវណ្ណ ឧត្តមវង្សី ហៅ តួ ចំពោះមុខមេធាវីការពារជនជាប់ចោទ សម្រេចបើកផ្លូវប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សា**

ហត្ថលេខានិងត្រា [redacted]

---

បានឃើញ

ថ្ងៃព្រហស្បតិ៍ ០៦រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ពស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

" បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍០៦រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ពស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner